ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

សាលក្រមព្រហ្មទណ្ឌលេខ៖៥៨៤ ច
ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៤
សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៣១៣
ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤
សំណុំរឿងស៊ើបសួរលេខ៖ ២៤៣
ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤
សំណុំរឿងជំនុំជម្រះលេខ៖ ៣៨៩
ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤

អាជ្ញាធរប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តក្រចេះ
សាលក្រម

បានបើកសវនាការជាអសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តក្រចេះ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ពីរកន្លះ, ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោងប្រាំបី និង នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ពីរ រសៀល ដោយមានសមាសភាពដូចខាងក្រោម៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោកស្រី [redacted] ចៅក្រមប្រឹក្សា
-លោក [redacted] ចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តក្រចេះ

ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តក្រចេះ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹង

ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖៣១៣ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សា ភេទប្រុស កើតឆ្នាំ២០០៩ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ថ្នាក់ទី៦ ទីកន្លែងកំណើត [redacted] ខេត្តក្រចេះ ទីលំនៅមុនថ្ងៃឃុំខ្លួននៅភូមិកាត់ដែ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] សាវិទ្ធិ (រ) ម្តាយឈ្មោះ [redacted] សុធា (រ) នៅលីវ អនីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៖ ២៣៣ ឃ.ខ/២៤ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

Scanned with CamScanner

២-ឈ្មោះ [redacted] ទួច ហៅ តួច ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦ ជាតិខ្មែរ សាសនា ព្រះពុទ្ធ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី៨ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តក្រចេះ ទីលំនៅមុនពេលឃុំខ្លួននៅភូមិស្នួលលិច ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] យ៉ាន់ (រ) ម្តាយឈ្មោះ [redacted]ខុំ (រ) នៅលើវ ជានីតិជន ទោសពីមុន គ្មាន។(ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៖ ២៥៨ ឃ.ខ/២៤ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ខេត្តក្រចេះ។

៣-ឈ្មោះ [redacted] លីពី ភេទប្រុស កើតថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៩ ជាតិខ្មែរ ទីកន្លែងកំណើតនៅ[redacted] ខេត្តក្រចេះ ទីលំនៅមុនថ្ងៃឃុំខ្លួននៅភូមិកាត់ដែ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] វាស្នា (រ) ម្តាយឈ្មោះ [redacted] ណារ៉ា (រ) ទៅលើវ ជាអនីតិជន ។(គេចខ្លួន)

-ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ៖ ១២៣ ច.ខ/២៤ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរនៃសាលា ដំបូងខេត្តក្រចេះ។

ជាប់ចោទពីបទ៖ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅចំណុចផ្លូវលំ ស្ថិតក្នុងភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា២០០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភាព ភេទស្រី (ម្តាយរបស់ជនរងគ្រោះ) កើតឆ្នាំ១៩៨៣ ជនជាតិខ្មែរ បច្ចុប្បន្ននៅភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ។

-បានឃើញ របាយការណ៍សំយោគលេខ៖១១២ /២៤ រ.ប.ក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ៖ ២៤៣ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៖ ២២៥ អ.ឃ.ក/២៤ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តក្រចេះ។

-បានឃើញ កំណត់ហេតុទទួលវត្ថុតាងលេខ៖ ១៤០ វ.ត ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូង ខេត្តក្រចេះ ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ៖២៧៦ អ.ឃ/២៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តក្រចេះ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖២២៩៩ ព.ស/២៤ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូង ខេត្តក្រចេះ។

<u>អង្គហេតុដែលធ្វើឲ្យមកតុលាការមានដូចតទៅ៖</u>

កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង២២ និង០០នាទី នៅចំណុចផ្លូវលំ ស្ថិតក្នុងភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ មានករណី ឃាតកម្មគិតទុកជាមុន បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] លីពី, ឈ្មោះ [redacted] ទួច និង ឈ្មោះ [redacted] សា ដែលមានទំនាស់ជាមួយជនរងគ្រោះឈ្មោះ [redacted] ទិត្យ ថារ៉ាក់ ភេទប្រុស អាយុ១៤ឆ្នាំ ហើយឈ្មោះ [redacted] ទិត្យថារ៉ាក់ បានយកដុំថ្មគប់មកលើឈ្មោះ [redacted] លីពី។ បន្ទាប់

Scanned with CamScanner

មកជនជាប់ចោទក៏បានជិះម៉ូតូមកឈប់ស្នាក់នៅចំណុចផ្លូវលំ ហើយនៅពេល ជនរងគ្រោះបានមកដល់ ស្រាប់តែក្រុមជនជាប់ចោទធ្វើសកម្មភាពយកដាវប្រវែង ៧៦ សង់ទីម៉ែត្រកាប់ទៅលើជនរងគ្រោះត្រូវ ចំហៀងក្បាលផ្នែកខាងស្តាំ បណ្តាលឱ្យដាច់ចេញឈាម និងប្រេះលលាក្បាលប្រវែង ១៤ សង់ទីម៉ែត្រ ហើយស្លាប់បាត់បង់ជីវិត នៅពេលបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកខេត្តក្រចេះ បន្ទាប់ពីធ្វើសកម្មភាពរួចជនជាប់ចោទបានជិះម៉ូតូគេចខ្លួន ។ ក្រោយមកដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជាន់ណា ភេទប្រុស អាយុ ៤៣ឆ្នាំ ដែលត្រូវជាអ៊ុំជនរងគ្រោះ បានប្តឹងរាយការណ៍ជូនសមត្ថកិច្ច ហើយសមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សា, ឈ្មោះ[redacted] ទូច និងកសាងសំណុំរឿងបញ្ជូនមកតុលាការ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

ចាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សា បានឆ្លើយថា៖ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង២២ និង០០នាទី ខ្លួននឹងឈ្មោះ [redacted] លីពី ភេទប្រុស និងឈ្មោះ[redacted] ទូច ភេទប្រុស បានជិះម៉ូតូ ០១គ្រឿង ម៉ាកវេរ្ឆាម ពណ៌ខ្មៅ គ្មានស្លាកលេខ នៅចំណុចផ្លូវលំ ស្ថិតនៅភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ដើម្បី ទៅឈ្លបស្តាក់ចាំកាប់ទៅលើជនរងគ្រោះ ដោយខ្លួនជាអ្នកនៅចាំលើម៉ូតូដែលមានចម្ងាយប្រហែលជា៣០ម៉ែត្រ ពីកន្លែងដែលឈ្លបស្តាក់នោះ ហើយឈ្មោះ [redacted] លីពី និងឈ្មោះ [redacted] ទូច ជាអ្នកឈ្លបស្តាក់ចាំកាប់ជនរងគ្រោះ ។ ខ្លួនមិនបានឃើញឈ្មោះ [redacted] លីពី និងឈ្មោះ [redacted] ទូច កាប់ទៅលើជនរងគ្រោះទេ ពីព្រោះពេលនោះគឺម៉ោង១០យប់ ទើបខ្លួនមិនអាចមើលឃើញឈ្មោះ [redacted] លីពី និងឈ្មោះ [redacted] ទូច កាប់ជនរងគ្រោះ ប៉ុន្តែពេលឈ្លបគេធ្វើសកម្មភាពហើយ ឈ្លបគេបានស្រែកឱ្យខ្លួនយកម៉ូតូទៅយកឈ្លបគេ ទើបខ្លួនដឹងថាឈ្មោះ [redacted] លីពី ជាអ្នកកាប់ទៅលើជនរងគ្រោះ ហើយឈ្មោះ [redacted] ទូច មិនបានកាប់ទេ។ ចំពោះមូលហេតុដែល ឈ្លបខ្លួននាំគ្នាទៅឈ្លបស្តាក់ចាំកាប់ជនរងគ្រោះ ដោយសារតែជនរងគ្រោះបានយកដុំថ្មគប់ទៅលើឈ្មោះ [redacted] លីពី ហើយឈ្មោះ [redacted] លីពី ក៏បានបបួលខ្លួន និងឈ្មោះ[redacted] ទូច ទៅឈ្លបស្តាក់ចាំកាប់លើជនរងគ្រោះតែម្តង ប៉ុន្តែចំពោះដាវដែលយកទៅកាប់ជនរងគ្រោះ គឺជាដាវរបស់ខ្លួន។ មុនពេលដែលឈ្លបខ្លួនទៅឈ្លបស្តាក់ជនរងគ្រោះ គឺឈ្លបខ្លួនបានជិះម៉ូតូ ១គ្រឿង មានគ្នា០៣នាក់ ហើយឈ្មោះ [redacted]លីពី ជាអ្នកឌុប ដោយខ្លួននឹងឈ្មោះ [redacted] ទូច ជិះពីក្រោយ។ ពេលនោះដែរ លីពី បានអោយខ្លួនចាំឈ្លបស្តាក់កាប់គេ ហើយដាវ គឺយកនៅផ្ទះខ្លួន ។ ឈ្មោះ លីពី ជាអ្នកឱ្យខ្លួនយកអោយវា ដើម្បីដាក់តាមម៉ូតូការពារខ្លួន ។ ពេលឃើញ ជនរងគ្រោះជិះម៉ូតចេញទៅបានប្រហែលកន្លះម៉ោង ឈ្លបខ្លួនក៏ចេញមកផ្ទះយកកាំបិត និងដាវ ស្រាប់តែជនរងគ្រោះជិះម៉ូតូមានគ្នាបីនាក់មកដល់កន្លែងដែលឈ្លបខ្លួន នៅរងចាំស្តាក់ចាំជនរងគ្រោះ ហើយឈ្មោះ [redacted] លីពី ក៏គប់ដាវទៅជនរងគ្រោះតែម្តង។ ចំពោះម៉ូតូដែលជិះទៅធ្វើសកម្មភាពគឺជាម៉ូតូរបស់ ឈ្មោះ [redacted] ទូច ហើយក្រោយពេលធ្វើសកម្មភាពហើយឈ្មោះ[redacted] លីពី បានចូលផ្ទះ ។ ដោយឡែកខ្លួន និងឈ្មោះ [redacted] ទូច បាន នៅអង្គុយលេងនៅវត្តផ្អាក ។ បន្ទាប់មកខ្លួន និង

ឈ្មោះ [redacted] ទូច បានជិះម៉ូតូទៅចំណុចត្រពាំងក្រហម ស្ថិតនៅក្នុងខេត្តរតនគីរី ហើយឈ្មោះ [redacted] ទូច បាន ត្រឡប់មកផ្ទះវិញ ហើយខ្លួនក៏ឡើងទៅស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ។ ពេលសមត្ថកិច្ចឃាត់ខ្លួន បានដកហូតទូរស័ព្ទចំនួន០១គ្រឿង ម៉ាក Iphone 7 ពណ៌ខ្មៅ ។

- ជនជាប់ចោទឈ្មោះ [redacted] ទូច បានឆ្លើយថា៖ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ប្រហែល០៨ឃប់ ខ្លួននិងឈ្មោះ [redacted] លីពី ភេទប្រុស អាយុប្រហែល១៦ឆ្នាំ និងឈ្មោះ [redacted] សា ភេទប្រុស អាយុ ប្រហែល១៥ឆ្នាំ បាននាំគ្នាទៅអង្គុយនៅ ម៉ាតមួយកន្លែង (មិនចាំឈ្មោះ ម៉ាត) ស្ថិតនៅឃុំស្នួល ស្រុកស្នួល ខេត្ត ក្រចេះ។ ពេលកំពុងអង្គុយនៅក្នុងម៉ាត ខ្លួនបានទៅអង្គុយក្បែរមិត្តភក្តិស្រីៗផ្សេងទៀត ចំណែកឈ្មោះ [redacted] លីពី និងឈ្មោះ [redacted] សា កំពុងលេងហ្គេម។ លុះដល់វេលាម៉ោង១១ឃប់ ខ្លួន ឈ្មោះ [redacted] លីពី និងឈ្មោ [redacted] សា បាន នាំគ្នា ជិះម៉ូតូចំនួន០១គ្រឿង ត្រឡប់ទៅផ្ទះវិញ ដោយម៉ូតូម៉ាកវ៉េវឆ្នាម ពណ៌ខ្មៅ គ្មានស្លាកលេខ ម៉ូតូរបស់ខ្លួន។ នៅពេលជិះចេញពីម៉ាតបានចម្ងាយប្រហែល៥០ម៉ែត្រ ស្រាប់តែមានជនមិនស្គាល់យកដុំថ្មគប់មកលើពួកខ្លួន ត្រូវធំក្បាលរបស់ខ្លួនបណ្តាលឱ្យពក ។ បន្ទាប់មកឈ្មោះ [redacted] លីពី បានបបួលខ្លួន និងឈ្មោះ [redacted] សា ទៅស្នាក់ កាប់ពួកនោះវិញ បន្ទាប់មកពួកខ្លួនបាននាំគ្នាជិះម៉ូតូទៅ ឃកដាវ ដែលឈ្មោះ [redacted] លីពី លាក់ទុកនៅក្នុងព្រៃ បន្ទាប់មកបានជិះម៉ូតូទៅផ្ទះរបស់ឈ្មោះ [redacted] សា យកកាំបិតផ្គាក់ចំនួន០១ ដើម ហើយកាំបិតផ្គាក់នេះគឺខ្លួនជា អ្នកកាន់ ចំណែកឈ្មោះ [redacted] លីពី ជាអ្នកកាន់ដាវ។ បន្ទាប់មកពួកខ្លួនបាននាំគ្នាអង្គុយចាំជន ដែលគប់ដុំថ្មមកលើ ពួកខ្លួននៅចំណុចខាងក្រោយប៉ុស្តិ៍នគរបាលស្នួល ស្ថិតនៅឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ខ្លួនមិនស្គាល់ ជនរង គ្រោះនោះទេ ដោយឈ្មោះ [redacted] លីពី ជាអ្នកស្គាល់ពួកនោះ។ ខ្លួន និងឈ្មោះ [redacted] សា បានយកម៉ូតូទៅអង្គុយចាំ នៅចម្ងាយ ពីកន្លែងកើតហេតុប្រហែល៥០ម៉ែត្រ ដោយឈ្មោះ [redacted] លីពី ជាអ្នកពួនស្ទាក់ចាំកាប់ជនរងគ្រោះ ម្នាក់ឯង ចំណែកខ្លួន និង ឈ្មោះ [redacted] សា អង្គុយចាំពេលដែលឈ្មោះ [redacted] លីពី កាប់រួចពួកខ្លួននាំគ្នាជិះម៉ូតូចេញ។ នៅពេលដែលពួកខ្លួនរង់ចាំបានមួយសន្ទុះ ក៏មានម៉ូតូចំនួន០១គ្រឿងជិះគ្នា០៣នាក់ បានជិះមកដល់កន្លែងដែល ឈ្មោះ [redacted] លីពី កំពុងស្ទាក់ចាំ ស្របពេលនោះខ្លួនបានឈឺជុះអាចម៍បានដើរចេញពីកន្លែងម៉ូតូចម្ងាយ ប្រហែលពាម៉ែត្រ ដោយខ្លួនបានកាន់កាំបិតផ្គាក់យកទៅជាមួយផងដែរ។ ពេលដែលខ្លួនកំពុងជុះអាចម៍ខ្លួនបាន ឮសម្តែងឈ្មោះ [redacted] លីពី ស្រែកថា កាប់ទៅៗ ដោយខ្លួនមិនបានឃើញសកម្មភាពទេ ចំណែកជនរងគ្រោះខ្លួន មិនបានឮសម្តែងស្រែកនោះទេ។ បន្ទាប់មកឈ្មោះ [redacted] លីពី បានរត់មកកន្លែងចាំម៉ូតូរួចឈ្មោះ [redacted] លីពី បាន ស្រែក ហៅខ្លួន ឱ្យមកត្រឡប់ទៅផ្ទះវិញ។ នៅពេលជិះត្រឡប់ទៅផ្ទះវិញឈ្មោះ [redacted] លីពី ជាអ្នកឌុបឈ្មោះ [redacted] សា ជិះកណ្តាល ចំណែកខ្លួនជិះខាងក្រោយកាន់កាំបិតផ្គាក់។ ពេលជិះម៉ូតូតាមផ្លូវឈ្មោះ [redacted] លីពី បានប្រាប់ពួក ខ្លួនថា គាត់បានគប់ដាវទៅលើជនរងគ្រោះចំនួន ០១ដាវ ជាប់នៅនឹងក្បាលរបស់ជនរងគ្រោះ។ បន្ទាប់មកឈ្មោះ [redacted] លីពី បានចូលផ្ទះរបស់គាត់ ចំណែកខ្លួន និង ឈ្មោះ [redacted] សា បានជិនម៉ូតូមកដល់ស្រុកឆ្នូង ខេត្តក្រចេះ បាន

Scanned with CamScanner

បោះកាំបិតផ្តាក់ចោលនៅក្នុងទីករួចខ្លួន និងឈ្មោះ [redacted] សា បានជិះម៉ូតរត់គេចខ្លួនទៅខេត្តរតនគីរី។ ក្រោយមកក៏រត់គេចខ្លួនទៅខេត្តស្វាយរៀង បានរយៈពេលប្រហែល០៥ថ្ងៃ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។ ចំពោះដាវ ដែលឈ្មោះ [redacted] លីពី គប់ទៅលើជនរងគ្រោះនោះ គឺជារបស់ឈ្មោះ [redacted] សា ហើយឈ្មោះ [redacted] សា ឱ្យទៅឈ្មោះ [redacted] លីពី តាំងពីពេលណានោះខ្លួនមិនដឹងនោះទេ ហើយចំពោះដាវដែលឈ្មោះ [redacted] លីពី លាក់ទុកនៅក្នុងព្រៃតាំងពីពេលណាមកនោះក៏ខ្លួនមិនដឹងដែរ។ ចំពោះជនរងគ្រោះខ្លួនមិនដែលស្គាល់នោះទេ ប៉ុន្តែឈ្មោះ កៅ លីពី ជាអ្នកស្គាល់ ហើយគាត់មានគំនុំអ្វីជាមួយជនរងគ្រោះក៏ខ្លួនមិនដឹងដែរ។ សកម្មភាពគប់ដាវទៅលើជនរងគ្រោះ នៅថ្ងៃកើតហេតុខ្លួនមិនបានត្រៀមរៀបចំទុកមុននោះទេ គឺដោយសារក្រុមជនរងគ្រោះគប់ដុំថ្មកលើពួកខ្លួន ទើបឈ្មោះ [redacted] លីពី បានបបួលខ្លួន និងឈ្មោះ [redacted] សា ទៅស្ទាក់កាប់តែម្តង។ ខ្លួនពុំធ្លាប់ប្រើប្រាស់គ្រឿងញៀននោះទេ ហើយក៏ពុំធ្លាប់មានទំនាស់ ឬ ធ្លាប់វាយគ្នាពីមុនមកដែរ ទើបតែលើកទី១ប៉ុណ្ណោះ។ នៅថ្ងៃដែលសមត្ថកិច្ចឃាត់រូបខ្លួនដកហូតបានខោអាវ ប្រហែល៤ ឬ៥កំប្លេ កាបូបចំនួន០១ (មានលុយប្រហែលបួនម៉ឺនរៀល) និងទូរស័ព្ទម៉ាក Iphone X ពណ៌ស ចំនួន០១គ្រឿង។

-ជនជាប់ចោទឈ្មោះ [redacted] សា បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃកើតហេតុខ្លួន រួមជាមួយឈ្មោះ [redacted] លីពី និងឈ្មោះ [redacted] ទូច បាននាំគ្នាទៅពួកស្ទាក់ចាំកាប់ជនរងគ្រោះ ដោយខ្លួនជាអ្នកអង្គុយចាំនៅកន្លែងម៉ូតូពីកន្លែងកើតហេតុចម្ងាយប្រហែល៣០ ម៉ែត្រ ចំណែកឈ្មោះ [redacted] លីពី និងឈ្មោះ [redacted] ទូច ជាអ្នកទៅពួនស្ទាក់កាប់ជនរងគ្រោះ ដោយឈ្មោះ [redacted] លីពី កាន់ដាវចំនួន០១ដើម និងឈ្មោះ [redacted] ទូច កាន់កាំបិតផ្តាក់ ចំនួន០១ដើម។ មួយសន្ទុះក្រោយមកឈ្មោះ [redacted] លីពី បានស្រែកហៅខ្លួនថា "អញ្ចេះគប់គេត្រូវហើយអាប់យកម៉ូតូមកឱ្យអញ្ចេះ" ពេលនោះខ្លួនបានជិះម៉ូតូទៅកន្លែងកើតហេតុបានឃើញឈ្មោះ [redacted] លីពី និងឈ្មោះ [redacted] ទូច កំពុងនៅកន្លែងនោះ ប៉ុន្តែខ្លួនមិនបានឃើញជនរងគ្រោះនោះទេ។ ចំពោះការពួនស្ទាក់កាប់នេះ ពួកខ្លួនពុំមានគម្រោងមុននោះទេ ដោយបន្ទាប់ពីក្រុមជនរងគ្រោះ គប់ពួកខ្លួនរួច ស្រាប់តែឈ្មោះ [redacted] លីពី បានបបួលខ្លួនទៅពួនស្ទាក់ចាំកាប់ជនរងគ្រោះតែម្តង។

-ជនជាប់ចោទ ឈ្មោះ [redacted] ទូច បានឆ្លើយបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុខ្លួន ពិតជាបានកាន់កាំបិតផ្តាក់ចំនួន ០១ដើម ចំណែកឈ្មោះ [redacted] លីពី កាន់ដាវចំនួន០១ដើម នៅពួនស្ទាក់ចាំ កាប់ជនរងគ្រោះពិតមែន ដោយឈ្មោះ [redacted] សា ជាអ្នកចាំម៉ូតូ។ ប៉ុន្តែពេលដែលខ្លួនដើរចេញពីកន្លែងម៉ូតូចម្ងាយប្រហែល ១០ម៉ែត្រ ខ្លួនបានឈឺជុះអាចម៍បានប្រាប់ឱ្យឈ្មោះ [redacted] លីពី ឱ្យទៅពួនស្ទាក់ចាំជនរងគ្រោះមុន ចំពេលខ្លួនឈឺអាចម៍រួចទើបខ្លួនទៅតាមក្រោយ ប៉ុន្តែពេលកំពុងជុះអាចម៍ ស្រាប់តែជនរងគ្រោះបានមកដល់ហើយក៏ត្រូវឈ្មោះ [redacted] លីពី គប់ដាវត្រូវតែម្តង ហើយខ្លួនបានកាន់កាំបិតរត់ទៅកន្លែងរបស់ឈ្មោះ [redacted] លីពី បន្ទាប់មកឈ្មោះ [redacted] សា ជិះម៉ូតូមកដល់តាមក្រោយ ឈ្មោះ [redacted] សា បានឆ្លើយថា ចំពោះកាំបិតផ្តាក់ចំនួន

Scanned with CamScanner

០១ដើម ដែលឈ្មោះ [redacted] ទូច កាន់ចាំកាប់ជនរងគ្រោះនោះ គឺឈ្មោះ[redacted] ទូច បានយកមកផ្ញើនៅផ្ទះខ្លួន ប្រហែល ០៨ថ្ងៃមុន ថ្ងៃកើតហេតុ ហើយនៅថ្ងៃកើតហេតុ ក៏បាននាំគ្នាជិះម៉ូតូទៅយកកាំបិតផ្គាក់នៅផ្ទះខ្លួនតែម្តង។ប៉ុន្តែចំពោះកាំបិតផ្គាក់នេះឈ្មោះ [redacted]ទូច យកមកពីណាខ្លួនមិនដឹងនោះទេ។ ឈ្មោះ [redacted] ទូច បានឆ្លើយថា ចំពោះកាំបិតផ្គាក់នេះពុំមែនរបស់ខ្លួនទេ ប៉ុន្តែខ្លួនបានយកកាំបិតផ្គាក់នេះទៅផ្ញើនៅផ្ទះរបស់ឈ្មោះ [redacted] សា មែន ដោយកាំបិតនេះ ជារបស់ឈ្មោះ និត ដែលយកផ្ញើនឹងខ្លួន ហើយខ្លួនក៏បានយកកាំបិតផ្គាក់មកផ្ញើនៅផ្ទះរបស់ឈ្មោះ [redacted] សា តែ ម្តង។ ជនជាប់ចោទឈ្មោះ [redacted] សា បានឆ្លើយថា ចំពោះសកម្មភាពដែលឈ្មោះ [redacted] លីពី គប់ទៅលើជនរងគ្រោះ ខ្លួនមិនបានឃើញដោយផ្ទាល់ភ្នែកនោះទេ ប៉ុន្តែពេលជិះម៉ូតូនៅតាមផ្លូវឈ្មោះ [redacted] លីពី បានប្រាប់ខ្លួន ដោយផ្ទាល់ថា គាត់ជាអ្នកគប់ទៅលើជនរងគ្រោះមួយដាវត្រូវចំក្បាល។ ឈ្មោះ [redacted] ទូច បានឆ្លើយថា ចំពោះ សកម្មភាពដែលឈ្មោះ[redacted] លីពី គប់ទៅលើជនរងគ្រោះ ខ្ញុំបាទមិនបានឃើញដោយផ្ទាល់ភ្នែកនោះទេ ប៉ុន្តែពេលជិះម៉ូតូនៅតាមផ្លូវឈ្មោះ [redacted] លីពី បានប្រាប់ខ្លួនដោយផ្ទាល់ថា គាត់ជាអ្នកគប់ដាវទៅលើជនរងគ្រោះមួយដាវត្រូវចំក្បាល។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភាព បានឆ្លើយថា៖ ខ្លួនជាម្តាយបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] ទិត្យថាវ៉ាក់ ចំពោះដើមបណ្តឹងឈ្មោះ [redacted] ផាន់ណា ត្រូវជាឪពុកមា របស់កូនខ្លួន ហើយគាត់ជាអ្នកទៅរាយការណ៍ប្រាប់សមត្ថកិច្ច ពេលនោះសមត្ថកិច្ចបានដាក់គាត់ជាដើមបណ្តឹង ចាប់ពីពេលនេះទៅខ្លួនសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីវិញ ។ នៅថ្ងៃកើតហេតុខ្លួនមិនបានឃើញសកម្មភាពផ្ទាល់ទេ ក្រោយពេលកើតហេតុប្អូនបានប្រាប់ទើបខ្លួនទៅមិត្តភក្តីរបស់កូនបានយកកូនខ្លួនទៅដល់មន្ទីរពេទ្យស្រុកស្នួលទៅហើយ ពេលខ្លួនទៅដល់ឃើញដាវពណ៌ខ្មៅជង់លើក្បាលកូនខ្លួន ហើយមន្ទីរពេទ្យក៏ដកដាវចេញបញ្ជូនកូនខ្លួនមកមន្ទីរពេទ្យខេត្តពេលមកដល់មន្ទីរពេទ្យកូនខ្លួនបានស្លាប់បាត់ទៅហើយ ។ ខ្លួនសុំទាមទារសំណងពីជនជាប់ចោទឈ្មោះ [redacted] សា ឈ្មោះ[redacted] ទូច និងឈ្មោះ[redacted] លីពី សរុបចំនួន ២៥០ .000.000 លានរៀល (ពីររយប្រាំសែសិបលាន)រៀល ។

-អំណានចម្លើយឈ្មោះ [redacted] ផាន់ណា បានឆ្លើយថា៖ កាលពីថ្ងៃមិនចាំខែឧសភា ឆ្នាំ២០២៥ វេលាម៉ោងប្រហែល ១១ យប់ ប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ណារី បានខលទូរសព្ទ៍ប្រាប់ថា ក្មួយឈ្មោះ [redacted] ទិត្យថាវ៉ាក់ ភេទប្រុស អាយុ ១៤ឆ្នាំ ត្រូវបានគេកាប់ ហើយឥឡូវត្រូវបានគេបញ្ជូនមកពេទ្យបង្អែកខេត្ត ហើយ។ បន្ទាប់មកខ្លួនក៏ទៅមើលក្មួយនៅមន្ទីរពេទ្យបង្អែកខេត្តក្រចេះ ហើយពេទ្យបានប្រាប់ថា ក្មួយហូរឈាមខ្លាំងពេកមិនអាចបញ្ចូលឈាមបានទេ ហើយគាត់ក៏បានស្លាប់នៅវេលាម៉ោងប្រហែល១២យប់។ ក្រោយមកខ្លួននិងម្តាយរបស់ជនរងគ្រោះ បានយកសាកសពក្មួយទៅធ្វើបុណ្យតាមប្រពៃណីខ្មែរ។ ព្រឹកឡើងខ្លួនទៅដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលស្រុកស្នួល។ នៅក្នុងរឿងនេះខ្លួនមិនបានឃើញជនសង្ស័យសម្លាប់ក្មួយ ដោយផ្ទាល់ទេតែបច្ចុប្បន្នជនជាប់ចោទនៅមិនទាន់ចាប់ខ្លួនបានទាំងអស់ទេ ហើយគ្រួសាររបស់ជនរងគ្រោះនៅមិនទាន់បាន

ទទួលសំណងនៅឡើយទេ។ ក្នុងនាមខ្លួនជាបងថ្លៃរបស់ម្តាយជនរងគ្រោះខ្លួនសូមទាមទារសំណងជំងឺចិត្តចំនួន ២៤០, ០០០,០០០(ពីររយសែសិបលាន)រៀល។

-អំណានកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ជឹងឈុង បានឆ្លើយថា៖ ខ្លួនត្រូវជាមិត្តភក្តិជាមួយជនរងគ្រោះឈ្មោះ [redacted] ទិត្យថារ៉ាក់ ភេទប្រុស អាយុ ១៤ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួលខេត្តក្រចេះ ហើយខ្លួនស្គាល់វាបានប្រហែល ៥ ថ្ងៃហើយ។ កាលពីថ្ងៃមិនចាំខែឧសភា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល ៩យប់ខ្លួនជិះម៉ូតូមួយគ្រឿង ម៉ាក ធូដេ ពណ៌ឈាមជ្រូក ដោយមានគ្នាពីរនាក់ ហើយខ្លួនជាអ្នកឌុបឈ្មោះ [redacted] ទិត្យថារ៉ាក់ និងឈ្មោះ ករណី ចេញពីហ្គារាស់សាំងនៅក្រោយផ្សារស្នួល ដើម្បីជូនឈ្មោះ [redacted] ទិត្យថារ៉ាក់ ទៅផ្ទះ។ ពេលពួកខ្លួនមកដល់ចំណុចផ្លូវលំស្ថិតក្នុងភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ស្រាប់ឈ្មោះ [redacted]លីពី និងឈ្មោះ ទូច បានរត់ចេញពីក្នុងព្រៃនៅចំណុចដីឡូត៍ ដោយឈ្មោះ [redacted] លីពី ជាអ្នកកាប់មកលើពួកខ្លួន ប៉ុន្តែខ្លួនបានគេចទាន់ ហើយក៏ត្រូវឈ្មោះ[redacted] ទិត្យថារ៉ាក់ ចំក្បាល ផ្នែកខាងស្តាំ ដោយជាប់ដាវនៅហ្នឹងក្បាលរបស់ឈ្មោះ [redacted] ទិត្យថារ៉ាក់ ។ បន្ទាប់មកខ្លួនបានបើកម៉ូតូចូលទៅផ្ទះរបស់គេនៅជិតទីនោះដែរ ដើម្បីឱ្យគេជួយ ហើយខ្លួនបានរត់ទៅហៅម្តាយរបស់ជនរងគ្រោះ ប៉ុន្តែមិនបានជួបម្តាយរបស់ជនរងគ្រោះទេ ដោយជួបបងរបស់ជនរងគ្រោះ។ ក្រោយមកបងរបស់ជនរងគ្រោះបានជូនខ្លួន និងឈ្មោះ [redacted] ទិត្យថារ៉ាក់ ទៅមន្ទីរពេទ្យបង្អែកស្រុកស្នួល ហើយពេទ្យបង្អែកស្រុកស្នួល បានបញ្ជូនជនរងគ្រោះមកពេទ្យបង្អែកខេត្ត ទើបឈ្មោះ [redacted] ទិត្យថារ៉ាក់ (ស្លាប់)។ នៅមុនពេលកើតហេតុខ្លួន និងឈ្មោះ [redacted] ទិត្យថា រ៉ាក់ និងឈ្មោះ ករណី បានទៅទិញអីញ៉ាំនៅក្នុងម៉ាតមួយកន្លែង ហើយបានជួបគ្នា ជាមួយក្រុមម្ខាងទៀតមានឈ្មោះ [redacted] លីពី និងឈ្មោះ ទូច និងម្នាក់ទៀតមិនស្គាល់ទេ ដោយនៅក្នុងម៉ាតក្រុមម្ខាងទៀតបាន ប្រើពាក្យសម្តីឌឺដងដាក់ពួកខ្លួន។ ខណៈនោះពួកខ្លួនបានចេញមកក្រៅម៉ាត ដោយបានជិះម៉ូតូយកទៅទុកកន្លែងមួយនៅក្នុងបុរីជេនី ហើយពួកខ្លួនបានរើសដុំថ្មតាមផ្លូវ ដើម្បីគប់ទៅក្រុមម្ខាងទៀត ដោយឈ្មោះ [redacted] ទិត្យថារ៉ាក់ និងឈ្មោះ ករណី បានគប់ដុំថ្មត្រូវ ជើងក្រុមម្ខាងទៀត ប៉ុន្តែខ្លួនមិនបានគប់ទេ។ លុះដល់ម៉ោងប្រហែល ៩ យប់ពួកខ្លួនបានជិះម៉ូតូជូនឈ្មោះ [redacted] ទិត្យថារ៉ាក់ មកផ្ទះក៏ត្រូវបានក្រុមម្ខាងទៀតកាប់តែម្តង។

-អំណានកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ករណី បានឆ្លើយថា៖ ខ្លួនត្រូវជាមិត្តភក្តិជាមួយជនរងគ្រោះឈ្មោះ [redacted] ទិត្យថារ៉ាក់ ភេទប្រុស អាយុ ១៤ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួលខេត្តក្រចេះ ហើយខ្លួនស្គាល់គ្នាបានប្រហែល ១ខែហើយ។ កាលពីថ្ងៃមិនចាំខែឧសភា ឆ្នាំ ២០២៤ វេលាម៉ោងប្រហែល១០យប់ខ្លួនជិះម៉ូតូមួយគ្រឿង ម៉ាកធូដេ ពណ៌ឈាមជ្រូក ជាមួយឈ្មោះ [redacted] ជឹងឈុង មានគ្នាពីរនាក់ ហើយឈ្មោះ [redacted] ជឹងឈុង ជាអ្នកឌុបខ្លួន និងឈ្មោះ [redacted] ទិត្យថារ៉ាក់ ខ្លួនជិះនៅខាង

ក្រោយគេ ចេញពីហ្គារាស់សាំងឈ្មោះ [redacted] គីមត្រាយ នៅភូមិ២ធ្នូ ដើម្បីជូនឈ្មោះ [redacted] ទិត្យថារ៉ាក់ ទៅផ្ទះ។ ពេលពួកខ្លួនជិះមកដល់ចំណុចក្រោយសាលាស្រុកស្នួល ត្រង់ចំណុចផ្លូវលំ ស្ថិតក្នុងភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ស្រាប់ឈ្មោះ [redacted] លីពី និងឈ្មោះ ទូច បានរត់ចេញពីក្នុងព្រៃ ដោយឈ្មោះ កៅ លីពី ជាអ្នកកាប់មកលើពួកខ្លួន ប៉ុន្តែមិនបានត្រូវខ្លួនទេ បែរជាត្រូវចំឈ្មោះ [redacted] ទិត្យថារ៉ាក់ ចំក្បាលផ្នែកខាងស្តាំ ដោយជាប់ដាវនៅហ្នឹងក្បាលរបស់ឈ្មោះ [redacted] ទិត្យថារ៉ាក់ ។ បន្ទាប់មកខ្លួនបានបើកម៉ូតូចូលទៅផ្ទះរបស់គេ ដែលនៅជិតផ្ទះរបស់ឈ្មោះ [redacted] ទិត្យថារ៉ាក់ ដើម្បីឲ្យគេជួយ ហើយឈ្មោះ [redacted] ជឹងឈុង បានរត់ទៅហៅម្តាយ របស់ជនរងគ្រោះ ប៉ុន្តែមិនបានជួបម្តាយរបស់ជនរងគ្រោះទេ ដោយជួបបងរបស់ជនរងគ្រោះ។ ក្រោយមកបង របស់ជនរងគ្រោះ និងឈ្មោះ [redacted] ជឹងឈុង បានជូនឈ្មោះ [redacted] ទិត្យថារ៉ាក់ ទៅមន្ទីរពេទ្យបង្អែកស្រុកស្នួល ហើយខ្លួនបានដឹងថា វាស្លាប់ក្រោយពេលបញ្ជូនមកដល់មន្ទីរពេទ្យបង្អែកខេត្តក្រចេះ។ នៅមុនពេលកើតហេតុ ខ្លួន ឈ្មោះ [redacted] ទិត្យថារ៉ាក់ និងឈ្មោះ [redacted] ជឹងឈុង បានទៅទិញអីញ្ចាំនៅក្នុងម៉ាតមួយ កន្លែងឈ្មោះ [redacted] គីមត្រាយ ហើយបានជួបគ្នាជាមួយក្រុមម្ខាងទៀតមានឈ្មោះ [redacted] លីពី ឈ្មោះ ទូច និងឈ្មោះ [redacted] សា ដោយ នៅក្នុងម៉ាតក្រុមម្ខាងទៀតបានប្រើពាក្យសម្តីឌឺដងដាក់ពួកខ្លួន។ខណៈនោះពួកខ្លួនបានចេញមកក្រៅម៉ាតដោយ បានជិះម៉ូតូយកទៅចុកកន្លែងមួយនៅក្នុងបុរីជេនី ហើយពួកខ្លួនបានរើសដុំថ្មតាមផ្លូវ ដើម្បីគប់ទៅក្រុមម្ខាង ទៀត ដោយឈ្មោះ [redacted] ទិត្យថារ៉ាក់ និងខ្លួនបានគប់ដុំថ្មត្រូវជើងឈ្មោះ [redacted] លីពី ប៉ុន្តែឈ្មោះ [redacted] ជឹងឈុង មិន បានគប់ទេ។ លុះដល់ម៉ោងប្រហែល ៩ឈប់ពួកខ្ញុំបាន ជិះម៉ូតូជូនឈ្មោះ [redacted] ទិត្យថារ៉ាក់ មកផ្ទះក៏ត្រូវបានក្រុម ម្ខាងទៀតកាប់តែម្តង។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកមេធាវីការពារសិទ្ធដើមបណ្តឹងរដ្ឋប្បវេណី

-បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ, ចម្លើយដើមបណ្តឹងរដ្ឋ ប្បវេណីឈ្មោះ [redacted] សុភាព ,អំណាងកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផាន់ណា , អំណាងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងភស្តុតាងនានាក្នុងសំណុំរឿង នាពេលសវនាការ ឃើញថា៖តាម ចម្លើយជនជាប់ចោទទាំងពី និងជនជាប់ចោទឈ្មោះ [redacted] ទូច បានឆ្លើយសារភាពថា អំពើដែលបង្កទៅលើ ជនរងគ្រោះ គឺកំពុងមានជម្លោះ និងភស្តុតាង មានកាំបិត និងដាវ ចឹងខ្លួនសំណូមពរសុំតុលាការផ្តន្ទាទោស ជនជាប់ចោទតាមច្បាប់កំណត់ និងសុំតុលាការចេញដីកាចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] លីពី រត់គេច ខ្លួន និងសុំតុលាការសម្រេចពីសំណងការខូចខាតដែលកើតចេញពីបទល្មើសដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុង ពាក្យបណ្តឹងនៃការទាមទារ ដោយសាបាត់បង់ក្បួយប្រុសម្នាក់ធ្ងន់ធ្ងរ ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភាព ចំពោះដើមបណ្តឹងឈ្មោះ [redacted] ផាន់ណា មិនទាមទារទេ ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-លោកព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូង ខេត្តក្រចេះ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ , អំណាងកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,អំណាង

Scanned with CamScanner

កំណត់ហេតុស្តាប់ចម្លើយសាក្សី និងភស្តុតាងនានាក្នុងសំណុំរឿង នាពេលសវនាការ តំណាងអយ្យការយល់ឃើញថា៖ ក្នុងរឿងនេះគឺផ្តើមឡើងដោយជនរងគ្រោះបានគប់មកលើជនជាប់ចោទមុន ហើយដោយសាខឹងការគប់របស់ជនរងគ្រោះ ជនជាប់ចោទទាំងបីនាក់បានជិះម៉ូតូទៅយកដាវ និងកាំបិត មកពួនស្នាក់បំណងពួនស្នាក់ប្រព្រឹត្តបទល្មើសលើជនរងគ្រោះ ពេលដែលជនរងគ្រោះជិះម៉ូតូមកដល់ក៏ប៉ះពាល់ដល់ជនរងគ្រោះ អំពើនេះជាអំពើមនុស្សឃាតដែលមានចែងតាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកមេធាវីការពារសិទ្ធជនជាប់ចោទ

-បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ, អំណានកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ,អំណានកំណត់ហេតុស្តាប់ចម្លើយសាក្សី និងភស្តុតាងនានាក្នុងសំណុំរឿងនាពេលសវនាការ ឃើញថា៖តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សា បានបញ្ជាក់ថា ទាំងកាំបិត និងដាវ គឺមានមុនពេលកើតហេតុ ហើយអំពើនេះមិនមែនបំណង ឬចេតនា សម្លាប់នៅទេ នេះជាអំពើហិង្សា បណ្តាលឲ្យស្លាប់ជនរងគ្រោះ ឡើយ ដូចនេះកូនក្តីខ្លួន ត្រូវបានក្រុមជនរងគ្រោះ គប់ត្រូវក្បាលមែន តែមិនមានគំនុំគំគួនចង់សម្លាប់នោះទេ បើជាគំនុំនោះគឺត្រូវកាប់ចិញ្ចាំតាមកំហឹង តែនេះគ្រាន់តែចែងឲ្យប៉ុណ្ណោះ ណាមួយកូនក្តីខ្លួនគ្រាន់តែសមគំនិតមិនបានគប់ផ្ទាល់ទេ អ្នកគប់គឺឈ្មោះ [redacted] លីពី ជាអ្នកគប់ដាវទៅត្រូវជនរងគ្រោះ ហើយជាចែងឲ្យគប់ទៅត្រូវក្បាលជនរងគ្រោះបណ្តាលឲ្យស្លាប់ ចឹងខ្លួនសំណូមពរសុំតុលាការពិចារណា ការផ្លាស់បទចោទពីមាត្រា ២០០ មកមាត្រា១៩៩ វិញ និងពិចារណាស្ថានសម្រាលកូនក្តីខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ។
-អំណានកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។
-អំណានកំណត់ហេតុស្តាប់ចម្លើយសាក្សី ។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវី។
-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា។
-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

<u>សំអាងហេតុ</u>

១.កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង២២ និង០០នាទី នៅចំណុចផ្លូវលំ ស្ថិតក្នុងភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ពិតជាមានករណីប្រើអាវុធកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] ទិត្យ ថារ៉ាក់ ត្រូវចំក្បាល និងបណ្តាលឲ្យស្លាប់បាត់បង់ជីវិតពេលទៅដល់មន្ទីពេទ្យ ប្រាកដមែន ។

២.តាមរយៈដីកាសម្រេចលេខ៖ ២២៩៩ ព.ស/២៤ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សា ភេទប្រុស, ឈ្មោះ [redacted] ទូច ភេទប្រុស និងឈ្មោះ [redacted] លីពី ភេទប្រុស មកតុលាការដើម្បីជំនុំជម្រះពីបទ៖ ឃាតកម្មគិតទុកជាមុន បទល្មើសប្រព្រឹត្តនៅចំណុចផ្លូវលំ ស្ថិត

Scanned with CamScanner

នៅក្នុងភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ប្រព្រឹត្តកាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និផ្តន្ទាទោសតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

៣.តាមរយៈចម្លើយសារភាពរបស់ជនជាប់ចោទ, អំណានចម្លើយរបស់សាក្សី, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កំណត់ហេតុដកហូតវត្ថុតាង និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថា នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ ដែលជាថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ [redacted] លីពី, ឈ្មោះ [redacted] សា និងឈ្មោះ [redacted] ទូច គឺមានជម្លោះជាមួយនឹងជនរងគ្រោះ ឈ្មោះ [redacted] ទិត្យថារ៉ាក់ នៅម៉ាតមួយកន្លែង ស្ថិតនៅឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ដោយជនជាប់ចោទ និងជនរងគ្រោះមានការឈឺឆងដាក់គ្នា ។ ក្រោយមកជនរងគ្រោះបានយកដុំថ្ម គប់ទៅលើក្រុមជនជាប់ចោទ បណ្តាលឲ្យត្រូវឈ្មោះ [redacted] លីពី ។ ក្រោយខឹងជនរងគ្រោះគប់ដុំថ្ម, ជនជាប់ចោទឈ្មោះ [redacted] លីពី បានបបួលជនជាប់ចោទឈ្មោះ [redacted] សា និងឈ្មោះ [redacted] ទូច ទៅចាប់ស្លាក់កាប់ជនរងគ្រោះវិញ ។ ដោយពេលនោះ ជនជាប់ចោទទាំងបីនាក់ បាននាំគ្នាជិះម៉ូតូទៅយកដាវដែលបានលាក់ក្នុងព្រៃ និងទៅយកកាំបិតផ្តាក់នៅផ្ទះរបស់ឈ្មោះ [redacted] សា ។ ក្រោយយកអាវុធបានហើយ ជនជាប់ចោទទាំងបីបាននាំគ្នាជិះម៉ូតូទៅចាំស្លាក់កាប់ជនរងគ្រោះ នៅក្រោយប៉ុស្តិ៍នគរបាលស្នួល ស្ថិតនៅឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ។ ពេលជនរងគ្រោះមកដល់ ជនជាប់ចោទឈ្មោះ [redacted] ទូច កាន់កាំបិតផ្តាក់ កំពុងនៅក្នុងព្រៃ ហើយជនជាប់ចោទឈ្មោះ [redacted] សា កំពុងយកម៉ូតូទៅលាក់នៅក្នុងព្រៃ និង ជនជាប់ចោទឈ្មោះ [redacted] លីពី ដែលចាំនៅលើផ្លូវ បានគប់ដាវសំដៅទៅជនរងគ្រោះបណ្តាលឲ្យដាវជាប់នឹងក្បាលជនរងគ្រោះ ហើយស្លាប់ពេលទៅដល់មន្ទីរពេទ្យ ។

៤.យោងតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌបានបញ្ជាក់ថា "ឃាតកម្មគិតទុកជាមុន គឺជាអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការឆ្លងស្មាក់ ។ ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើប៉ៃតប៉ៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។ ការឆ្លងស្មាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើប៉ៃតប៉ៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ" ។ មានន័យថា អំពើមួយត្រូវកំណត់ថាជាអំពើឃាតកម្មគិតទុកជាមុន កាលណាអំពើឃាតកម្មនោះត្រូវបានប្រព្រឹត្តដោយការរៀបចំគម្រោងដែលបង្កើតឡើងជាមុន ឬ ជាអំពើឃាតកម្មដែលប្រព្រឹត្តដោយមានការឃ្លាំចាំជាមុន ។

៥.ផ្អែកតាមសំអាងហេតុនៅចំណុចទី៣ និងទី៤ ខាងលើ ឃើញថាអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លីពី, ឈ្មោះ [redacted] សា និងឈ្មោះ [redacted] ទូច ដែលបាននាំគ្នាយកកាំបិត និងដាវ ទៅចាំជនរងគ្រោះនៅព្រៃ ហើយពេលជនរងគ្រោះទៅដល់ កាប់សំដៅក្បាលជនរងគ្រោះ នោះ គឺជាការសម្លាប់ដោយការឆ្លងស្មាក់ ដែលត្រូវកំណត់ថាជាអំពើឃាតកម្មគិតទុកជាមុន ស្របតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

Scanned with CamScanner

៦. ជនជាប់ចោទមានកម្រិតអាយុអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។ ប៉ុន្តែ ជនជាប់ចោទទាំងបី គឺជាអនីតិជនដែលមានអាយុ ក្រោម១៨ឆ្នាំ គប្បីតុលាការពិចារណាការប្រកាសទោសស្របតាមមាត្រា ១៦០ កថាខណ្ឌទី១ ចំណុច១ និងចំណុច៣ នៃក្រមព្រហ្មទណ្ឌ ។

៧. ជនជាប់ចោទប្រាកដជាយល់ដឹងច្បាស់ថា ខ្លួនពុំត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដូចការចោទប្រកាន់ខាងលើនោះទេ ប៉ុន្តែខ្លួននៅតែប្រព្រឹត្តដោយចេតនាទុច្ចរិតដែលច្បាប់បញ្ញត្តិថាជាបទល្មើស និងផ្តន្ទាទោស ។

៨. អំពើរបស់ជនជាប់ចោទបានប៉ះពាល់ធ្ងន់ធ្ងរដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ។

៩. សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

១០. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

១១. សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

១២. ឈ្មោះ [redacted] សុភាព គឺជាម្តាយរបស់ជនរងគ្រោះឈ្មោះ [redacted]ទិត្យថារ៉ាក់ បានចូលរួមក្នុងកិច្ចពិភាក្សាដេញដោលនាពេលសវនាការ ដោយស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជំនួសឱ្យឈ្មោះ [redacted] ផាន់ណា ដែលត្រូវជាឪពុករបស់ជនរងគ្រោះ ។ ហេតុនេះ គប្បីតុលាការទទួលស្គាល់ឈ្មោះ [redacted] សុភាព មានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមមាត្រា ១៦ និងមាត្រា ៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១៣. ជនជាប់ចោទទាំងបី គឺជាអនីតិជនអាយុក្រោម១៨ឆ្នាំ ហេតុពុំទាន់មានលទ្ធភាពទទួលខុសត្រូវផ្នែករដ្ឋប្បវេណីនៅឡើយ ។ គប្បីតុលាការកំណត់ឱ្យអាណាព្យាបាលរបស់ជនជាប់ចោទ មានឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

១៤. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] សា ភេទប្រុស, ឈ្មោះ [redacted] ទូច ភេទប្រុស និងឈ្មោះ [redacted] លីពី ភេទប្រុស មកតុលាការដើម្បីជំនុំជម្រះពីបទ៖ ឃាតកម្មគិតទុកជាមុន បទល្មើសប្រព្រឹត្តនៅចំណុចផ្លូវលំ ស្ថិតនៅក្នុងភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ប្រព្រឹត្តកាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និផ្តន្ទាទោសតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

១៥. វត្តុតាងរួមមាន៖ ដាវ ប្រវែង ៧៦ សង់ទីម៉ែត្រ ០១ដើម គប្បីតុលាការសម្រេចស្របតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

Scanned with CamScanner

១៦. ដើមបណ្តឹងរដ្ឋប្បវេណី បានទាមទារសំណងពីជនជាប់ចោទទាំងបីសរុបជាទឹកប្រាក់ចំនួន ២៤០លានរៀល ។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

១៧. ក្រោយពេលប្រព្រឹត្តបទល្មើសរួច ជនជាប់ចោទឈ្មោះ [redacted]លីពី គេចខ្លួនមិនចូលខ្លួនទទួលខុសត្រូវនូវទង្វើរបស់ខ្លួនឡើយ ។ គប្បីតុលាការសម្រេចចាប់ខ្លួនជនជាប់ចោទ ស្របតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ហេតុផ្លូវច្បេះសម្រេច

១/-ផ្តន្ទាទោសលើជនជាប់ចោទ

ក- ឈ្មោះ [redacted] សា ភេទប្រុស កើតនៅឆ្នាំ២០០៩ (អនីតិជន) ដាក់ពន្ធនាគារកំណត់២០ ឆ្នាំ (ម្ភៃ)ឆ្នាំ (ក្នុងឃុំ)។

ខ- ឈ្មោះ [redacted] ទួច ភេទប្រុស កើតនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦ (អនីតិជន) ដាក់ពន្ធនាគារកំណត់២០ ឆ្នាំ (ម្ភៃ)ឆ្នាំ (ក្នុងឃុំ)។

គ-ឈ្មោះ [redacted] លីពី ភេទប្រុស កើតនៅ១៨ ខែមករា ឆ្នាំ២០០៩ (អនីតិជន) ដាក់ពន្ធនាគារកំណត់២០ ឆ្នាំ (ម្ភៃ)ឆ្នាំ (គេចខ្លួន)។

ពីបទ៖ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅចំណុចផ្លូវលំ ស្ថិតក្នុងភូមិផ្សារស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញាតិមាត្រា២០០ និងមាត្រា ១៦០ កថាខណ្ឌ២ នៃក្រមព្រហ្មទណ្ឌ ។

២/-បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] លីពី ភេទប្រុស កើតនៅ១៨ ខែមករា ឆ្នាំ២០០៩ តាមបញ្ញាតិមាត្រា ៣៥៣ នៃនីតិវិធីក្រមព្រហ្មទណ្ឌ ។

៣/-បង្គាប់ឲ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណី៖

-ឈ្មោះ [redacted] សៅសារិទ្ធិ និងឈ្មោះ [redacted] សុធា (ឪពុក ម្តាយជនជាប់ចោទឈ្មោះ [redacted] សា) សងសំណង ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទិត្យ សុភាព ភេទស្រី ចំនួន ៤០.០០០.០០០ ៛ (សែសិបលាន)រៀល។

-ឈ្មោះ [redacted] ខុំ និងឈ្មោះ [redacted] យ៉ាន់ (ឪពុក ម្តាយជនជាប់ចោទឈ្មោះ [redacted] ទួច) សងសំណងឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទិត្យ សុភាព ភេទស្រី ចំនួន ៤០.០០០.០០០ ៛ (សែសិបលាន)រៀល។

-ឈ្មោះ [redacted] វាស្នា និងឈ្មោះ [redacted] ណារ៉ា (ឪពុក ម្តាយជនជាប់ចោទឈ្មោះ [redacted] លីពី) សងសំណង ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភាព ភេទស្រី ចំនួន ៤០.០០០.០០០ ៛ (សែសិបលាន)រៀល។

៤/-រឹបអូសវត្ថុតាង គឺ ដាវ ប្រវែង ៧៦ សង់ទីម៉ែត្រ ០១ដើម តាមបញ្ញាតិមាត្រា៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៤ និងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ និងថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ និងប្រកាសជាអសាធារណៈនៅថ្ងៃទី០៧ ខែវិច្ឆិកា

Scanned with CamScanner

ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សា ភេទប្រុស កើតនៅឆ្នាំ២០០៩ , ឈ្មោះ [redacted] ទួច ភេទប្រុស កើតនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៦ ,កំពុងមុខជនជាប់ចោទឈ្មោះ [redacted] លីពី ភេទប្រុស កើតនៅ១៨ ខែមករា ឆ្នាំ២០០៩ ចំពោះមុខដើបបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភាព ភេទស្រី និងចំពោះមុខអ្នកទទួលខុសត្រូវជនជាប់ចោទឈ្មោះ [redacted] ទួច កំពុងមុខអ្នកទទួលខុសត្រូវជនជាប់ចោទឈ្មោះ [redacted] សា ឈ្មោះ [redacted] សុធា ឈ្មោះ [redacted] វាសនា ។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ត្រឡាបញ្ជីសវនាការ ចៅក្រមប្រកួក្សា ចៅក្រមប្រកួក្សា ប្រធានក្រុមប្រឹក្សាដំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

សាលក្រមនេះបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស/២៥៦៨
ធ្វើនៅក្រចេះ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៤
ត្រឡាបញ្ជីសវនាការ

[redacted]

ថានឃើញ
ប្រធានក្រុមប្រឹក្សាដំនុំជម្រះ

[redacted]

Scanned with CamScanner